ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

**អង្គភាពគាំពារជនរងគ្រោះ**
**Victims Support Section**
**Section d'appui aux victimes**

ភ្នំពេញ ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១១

# សេចក្តីប្រកាសព័ត៌មាន

## វេទិកាថ្នាក់តំបន់លើកទី៤ សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង០០២

អង្គភាពគាំពារជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) នឹងរៀបចំវេទិកា ថ្នាក់តំបន់លើកទី៤ សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង០០២ ចំនួន **៣០០** នាក់ មកពីតំបន់ភាគខាងជើងនៃប្រទេសកម្ពុជា ដែលរួមមានខេត្តកំពង់ស្ពឺ បាត់ដំបង ពោធិសាត់ និងកំពង់ឆ្នាំង។ វេទិកាថ្នាក់តំបន់លើកទី៤នេះនឹងប្រព្រឹត្តិទៅនៅ **ថ្ងៃព្រហស្បតិ៍ ទី២៤ ខែមីនា ឆ្នាំ២០១១ នៅសណ្ឋាគាររស្មីសុខាញូវយ៉ក ខេត្តកំពង់ឆ្នាំង ចាប់ពីម៉ោង ៧:៣០ ព្រឹក** (*អត្តសញ្ញាណរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានរក្សាការសម្ងាត់*)។

វេទិកាថ្នាក់តំបន់នេះមានបំណងលើកកម្ពស់ការចូលរួមរបស់ជនរងគ្រោះដែលជាដើមបណ្តឹងរដ្ឋប្បវេណី និងផ្តល់ឱកាសឲ្យដើមបណ្តឹងរដ្ឋប្បវេណីជួបជាមួយ ៖

- មេធាវីដើមបណ្តឹងរដ្ឋប្បវេណីដើម្បីពិភាក្សាអំពីសិទ្ធិក្នុងការដាក់ពាក្យបណ្តឹង នីតិវិធីចូលរួមនៅក្នុងដំណើរការកាត់ក្តី ក៏ដូចជា ប្រមូលគំនិតដែលពាក់ព័ន្ធនឹងសំណងដែលស្នើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីរៀបចំគម្រោងសំណងនិងស្នើទៅកាន់ អ.វ.ត.ក ។
- មន្ត្រីមកពីការិយាល័យនានានៃ អ.វ.ត.ក និងតំណាងសង្គមស៊ីវិល ដើម្បីស្វែងយល់ពីការវិវឌ្ឍន៍ថ្មីៗរបស់តុលាការ។
- ដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង ០០១ ដើម្បីចែករំលែកបទពិសោធន៍សម្រាប់សំណុំរឿង០០២។

វេទិកាថ្នាក់តំបន់នេះគឺជាសកម្មភាពមួយសំខាន់ក្នុងចំណោមសកម្មភាពនានារបស់អង្គភាពគាំពារជនរងគ្រោះ ក្នុងការអនុវត្តគម្រោងនៃការចូលរួមរបស់ជនរងគ្រោះ ដើម្បីពង្រឹងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងដំណើរការសំណុំរឿង០០២។ នៅក្នុងវេទិកាថ្នាក់តំបន់ចំនួន៣លើកមុន ដើមបណ្តឹងរដ្ឋប្បវេណីចំនួនជាង ១៣០០នាក់ មកពី១៨ខេត្តក្រុង បានចូលរួម។

វេទិកាថ្នាក់តំបន់លើកទី៥នឹងរៀបចំនៅខេត្តសៀមរាបនៅចុងខែមេសា ធ្វើយ៉ាងណាឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ ចំនួនជាង២០០០នាក់ បានជួបតំណាងផ្លូវច្បាប់របស់ខ្លួនក៏ដូចជាមន្ត្រីនានាមុនដំណើរការនៃសវនាការសំណុំរឿង ០០២។

**ព័ត៌មានបន្ថែម សូមទាក់ទង៖**

លោក អ៊ឹម សុភា

ប្រធានកម្មវិធីផ្សព្វផ្សាយនៃអង្គភាពគាំពារជនរងគ្រោះ

ទូរស័ព្ទលេខ ០៧៧ ៧៧៧ ៣៦៧

សារអេឡិកត្រូនិក: im.sophea@eccc.gov.kh